# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុន CHAMLAB ម៉ាឡេស៊ី



នៅព្រឹកថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមនិងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួង បានទទួលជួបប្រតិភូនៃ ក្រុមហ៊ុន CHAMLAB មកពីប្រទេសម៉ាឡេស៊ី ដឹកនាំដោយលោក **Dato´MARCUSK.F.KAM** អគ្គនាយកក្រុមហ៊ុន ដើម្បីពិភាក្សាការងារ និង ស្តាប់បទឧទ្ទេសនាមពីប្រតិភូក្រុមហ៊ុន ស្តីពីការងារបច្ចេកទេសទាក់ទងវិស័យទឹកស្អាត និង កត្តាសុខភាព សុវត្ថិភាព និងបរិស្ថាន ក្នុងវិស័យឧស្សាហកម្មកម្ពុជា ដែលជាមុខសញ្ញាអាជីវកម្មរបស់ក្រុមហ៊ុន ។

បន្ទាប់ពីឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងការស្វាគមន៍ និងបង្ហាញពីការចាប់អារម្មណ៍ពីមុខសញ្ញា អាជីវកម្មរបស់ក្រុមហ៊ុនរួចមក មន្ត្រីជំនាញរបស់ក្រុមហ៊ុន បានធ្វើបទបង្ហាញពីគោលបំណងផ្នែកបច្ចេកទេសរបស់ខ្លួន នៅ កម្ពុជា ទាក់ទងអំពីការវិភាគ និងការវាយតម្លៃបញ្ជាក់ការធ្វើប្រព្រឹត្តិកម្មទឹក និងបទឧទ្ទេសនាម អំពីការបញ្ជាក់និងការត្រួតពិនិត្យ វាយតម្លៃ ពីកត្តាសុខភាព សុវត្ថិភាព និងបរិស្ថាន សម្រាប់វិស័យឧស្សាហកម្ម ដោយក្រុមហ៊ុន បានបង្ហាញពី និតិវិធី ដំណើរការ ជំនាញ បទពិសោធន៍ នៃការធ្វើតេស្តវិភាគ ដោយមន្ទីរពិសោធន៍ដែលមានឧបករណ៍ទំនើប និងមន្ត្រីដែលមានជំនាញ និងលើកឡើងពីផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ក្រោមគោលការណ៍ដៃគូ ឯកជនសាធារណៈ **(Public Private Parnership)** ព្រមទាំងបង្ហាញជំហរក្នុងកិច្ចសហការ សម្រាប់គម្រោងវិនិយោគ នៅ កម្ពុជាផងដែរ ។





ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបង្ហាញនូវការចាប់អារម្មណ៍ចំពោះបទពិសោធន៍ និងជំនាញរបស់ក្រុមហ៊ុន ។ ទាក់ទងនិងវិស័យទឹកស្អាត ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពបង្កើតមន្ទីរពិសោធន៍នៅតាមបណ្តាខេត្តមួយចំនួន ដែលអាចធ្វើតេស្តពិសោធន៍បានសម្រាប់រដ្ឋាករទឹកខេត្ត រឺស្ថានីយ៍ទឹកស្អាតឯកជន ដោយមិនពិបាកការដឹកកុំរូទឹកយកមកពិសោធន៍នៅរដ្ឋាទឹកស្វ័យតរាជធានីភ្នំពេញ ពីព្រោះការធ្វើតេស្តទឹកស្អាតនេះត្រូវធ្វើជារឿយៗ និងទៀងទាត់បំផុត ហើយក៏ស្របពេលដែលក្រសួងកំពុងយកចិត្តទុកដាក់ ការអភិវឌ្ឍន៍វិស័យទឹកស្អាតឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហសវត្សន៍ និងគោរពតាមគោលការណ៍យ៉ាងហោច ០៤ យ៉ាង គឺៈគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ ។ ចំពោះការងារត្រួតពិនិត្យ និងវាយតម្លៃបញ្ជាក់ លើកត្តាសុខភាព សុវត្ថិភាព និងបរិស្ថាន ឯកឧត្តម ទេសរដ្ឋមន្ត្រី បានចាត់ទុកជាការងារសំខាន់មួយ សម្រាប់ឧស្សាហកម្មនៅកម្ពុជា ដើម្បីឱ្យមានភាពអនុលោមទៅតាមច្បាប់កំណត់ផង និងអាចការពារសុវត្ថិភាព សុខភាព និងគោរពគោលការណ៍បរិស្ថានល្អប្រសើរផង ។ ចំណុចទាក់ទងខាងលើ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកទឹកចិត្តឱ្យក្រុមហ៊ុន បង្កើតមន្ទីរពិសោធន៍ឱ្យបានច្រើនតាមដែលអាចធ្វើបាន

ទាំងរាជធានី និងខេត្ត ក្រុង រួមទាំងបង្កើតមន្ទីរពិសោធន៍ចល័តតាមរថយន្តផងដែរ សម្រាប់ទីតាំងធ្វើតេស្តដែលនៅឆ្ងាយ ។ ជាមួយគ្នា នេះ ឯកឧត្តម បានស្នើឱ្យសហការចាប់ដៃគ្នា ជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបច្ចុប្បន្នក្រសួង មានមន្ទីរពិសោធន៍ឧស្សាហកម្ម ហើយវិទ្យាស្ថានស្តង់ដា ក៏មានមន្ទីរពិសោធន៍របស់ខ្លួនផងដែរ ។ ដោយឡែក ទាក់ទង និងកិច្ចការពារសុវត្ថិភាពចរាចរណ៍តាមដងផ្លូវ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាព បង្កើតស្ថានីយ៍ពិសោធន៍តាមដងផ្លូវ ដើម្បីត្រួតពិនិត្យមើលយានយន្ត ដែលធ្វើចរាចរណ៍ តើបានបំពេញតាមលក្ខណៈបច្ចេក ទេសបានត្រឹមត្រូវវីយ៉ាងណា? ព្រោះទាក់ទង និងសុវត្ថិភាព ទាំងអ្នកបើកបរ អ្នកធ្វើដំណើរជាមួយ និងអ្នកដ៏ទៃ ។ ទន្ទឹមគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានលើកឡើង ពីតម្រូវការនៅកម្ពុជា ទាក់ទងនិងការវិនិយោគនូវមន្ទីរពិសោធន៍ សម្រាប់ចំណីអាហារ ពិសោធន៍លើអំបោះ ក្រណាត់ និងត្បូងពេជ្រជាដើម ។ ពីព្រោះកម្ពុជាមានសេដ្ឋកិច្ចពឹងផ្អែកលើការ នាំចេញ ដែលទំនិញ រឺផលិតផល ត្រូវតែគោរពតាមក៏រិតស្តង់ដា និងអាចប្រកួតប្រជែងបាន ។



លោក **Dato´MARCUSK.F.KAM** អគ្គនាយកក្រុមហ៊ុន CHAMLAB បានឯកភាពចំពោះការស្នើនិងការផ្តល់ អនុសាសន៍ណែនាំរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ហើយក្រុមហ៊ុននឹងចាប់ផ្តើមអនុវត្តការងារនេះក្នុងដំហ៊ានជាបណ្តើរៗ នាពេលឆាប់ៗខាងមុខនេះ ។